# ការសំភាសន៍របស់អ៊ំប្រុស អ៊ុំ វណ្ណៈ

កៈ អ្នកធ្វើការសំភាសន៍ឈ្មោះ ញ៉ែម សុគន្ធា ខៈ អ្នកត្រូវគេសំភាសន៍ឈ្មោះ អ៊ុំ វណ្ណៈ

## <u>ការសង្ខេបរបស់អ៊ុំ វណ្ណ</u>

អ៊ុំ វណ្ណ គាត់ជាកូនទោលនៅក្នុងត្រកូលមួយដ៏មានសំបូរបែបនៅមុនជំនាន់ប៉ុល ពត ឪពុកជាម្នាក់ដែលធ្វើការនៅក្នុងស្ថានទូតអាមេរិច ។គាត់រៀនបានយ៉ាងខ្ពង់ខ្ពស់ហើយគាត់ចេះនិយាយ ភាសាបារាំង គាត់ចេះតែងកំណាព្យ ហើយគាត់បានតែងពេលនៅក្នុងរបបសង្គ្រាមប៉ុន្តែគាត់តែងតឺនៅចាំនៅក្នុងគំនិតរបស់គាត់តែប៉ុណ្ណោះព្រោះខ្លាចគេយកទៅសំលាប់ចោល។ គាត់បានធ្វើការយ៉ាងខ្លាំងនៅក្នុងរបបប៉ុល ពត ដើម្បីបានអាហារហូប។

កៈ ញ៉ុមសូមថ្លែងអំណរគុណដល់ប៉ាប៉ាដែលអោយខ្ញុំសំភាសន៍អំពីជីវប្រវត្តិញ៉ុមឈ្មោះ អ៊ុំ ប្រសិទ្ធ ជាអ្នកសំភាសន៍ឈ្មោះពេញរបស់ប៉ាឈ្មោះអ្វី?

ខៈ អ៊ុំ វណ្ណៈ។

កៈ ថ្ងៃនេះខ្ញុំសំភាសន៍គឺនៅក្នុងថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ ។ការសំភាសន៍នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យនៅប្រទេសអាមេរិចឈ្មោះថា ប៊ី វ៉ាយ យូ សកលវិទ្យាល័យមានកម្មវិធីដើម្បីសំភាសន៍អំពីជីវប្រវត្តិរបស់លោកប៉ានឹងប្រជាជនខ្មែរដើម្បីពេលអនាគតទៅមុខទៅកូនចៅរបស់លោកប៉ានឹងមនុស្សជំនាន់ក្រោយអាចដឹងពីជីវប្រវត្តិនិងដំនើររឿងឆាកជីវិតរបស់ដូនតា តើលោកប៉ាអនុញ្ញាតអោយខ្ញុំដាក់ការសំភាសន៍ចូលទៅក្នុងវេបសាយរបស់សកលវិទ្យាល័យ ប៊ី វ៉ាយ យូ ដែរឬទេ?

ខៈ បាន!!!

កៈ ដែលវេបសាយនោះមានឈ្មោះថា www.cambodiaoralhistory.byu.edu ញ៉ុមសូមចាប់ផ្តើមធ្វើការសំភាសន៍។សូមប្រាប់ឈ្មោះពេញរបស់ប៉ាម្តងទៀត?

ខៈ ឈ្មោះ អ៊ុំ វណ្ណៈ។

កៈ តើមានឈ្មោះគេហៅក្រៅដែរឬទេ?

គៈ ឈ្មោះអីគេអ៊ុំ?

ខ៖ ឈ្មោះ អានាង អានុយ អីផ្សេងៗហ្នឹង!!!

ក៖ តើប៉ាកើតនៅថ្ងៃទីខែឆ្នាំណា?

ខ៖ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៥៦។

ក៖ ៥៦(១៩៥៦)!! ទីកន្លែងកំណើតនៅឯណា?

ខ៖ នៅឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

ក៖ តើឆ្នាំខ្មែរជាសត្វអ្វី?

ខ៖ ជាសត្វស្វា។

ក៖ តើមានបងប្អូនប្រុសស្រីប៉ុន្មាននាក់?

ខ៖ មានច្រើនណាស់មានម្នាក់ឯង!!!មានម្នាក់ឯងទេ មានម្នាក់ឯង!!

ក៖ កូនទោល!!

ក៖ កូនទោលចឹង!!

ខ៖ ហ្នឹង!!

ក៖ ចឹងអត់មានកូនទីប៉ុន្មានទេ!!ចឹង

ខ៖ អត់មានប៉ុន្មានទេកូនទី១។

ក៖ ទី១!!តើឪពុកឈ្មោះអ្វី?

ខ៖ ឈ្មោះ អ៊ុំ គូ។

ក៖ ទីកន្លែងកំណើត?

ខ៖ អើនៅភូមិពន្លៃ ឃុំទ្រា ស្រុកកណ្តាលស្ទឹងខេត្តកណ្តាល។

ក៖ កើតនៅថ្ងៃខែឆ្នាំណា?

ខ៖ ខ្ញុំអត់ដឹង។

ក៖ (អានពីសំបុត្រកំណើត( ប៉ាកើតថ្ងៃទី១៣ខែធ្នូ ឆ្នាំ១៩១១))។ឆ្នាំខ្មែរជាសត្វអ្វី?

ខ៖ គាត់ប្រហែលជាឆ្នាំរោងហើយមើលទៅ!!

ក៖ ឆ្នាំរោង!! តើគាត់ស្លាប់ឬក៏នៅរស់?

ខ៖ គាត់ស្លាប់ហើយ គាត់ស្លាប់តាំងពីឆ្នាំ១៩៧៥ហ្ន៎!!ខែវិច្ឆិកា!!ថ្ងៃទី២ខែវិច្ឆិកាឆ្នាំ១៩៧៥។

ក៖ នៅសម័យណាដែរ?

ខ៖ នៅសម័យប៉ុល ពត។

ក៖ នៅសម័យប៉ុល ពត!! តើមានការចងចាំអ្វីខ្លះជាមួយនឹងគាត់?

ខ៖ អើពេលគាត់កំពុងស្លាប់គាត់កំពុងឃ្វាលគោ!!ឃ្វាលគោ និយាយរួមទៅគាត់ខ្វះខាតការហូបចុកហា៎!!គាត់កាច់ពោតនៅមុខផ្ទះហ្នឹងហើយគាត់ដួលស្លាប់នឹងម៉ង!!

ក៖ អ៊ុំមានចងចាំអីគេខ្លះពីគាត់ទេ?ដូចជាគាត់ប្រៀបប្រដៅអ៊ំម៉េចដែរចឹងហា៎?

ខ៖ គាត់ប្រៀបប្រដៅកូនអោយធ្វើអ្វីៗដែលល្អហើយត្រឹមត្រូវ!!ដោយសារពីមុនមកគាត់ធ្វើការនៅស្ថានទូតអាមេរិចកាំង អើគាត់អ្នកមានបបូរមែនទែន!!ដោយគាត់ទៅសម័យអាពតនេះគាត់ខ្វះខាតហា៎!!ហូបចុកខ្វះខាតហា៎!! គាត់ធាត់រហូត គាត់ធាត់រហូតដល់គាត់ស្លាប់ម៉ង អត់មានស្គមអីទេគាត់ហ្នឹង។

ក៖ តើម្ដាយឈ្មោះអ្វី?

ខ៖ ឈ្មោះម៉ែន សេម។គាត់ស្លាប់បាត់ហើយ។

ក៖ កើតនៅថ្ងៃខែឆ្នាំណា?

ខ៖ ខ្ញុំអត់ចាំទេ។

ក៖ ប្រហែលជាមើលក្នុងសំបុត្រកំណើត។

ក៖ ក្នុងសំបុត្រកំណើតមាន ចឹងសំបុត្រកំនើតអើម្ដាយកើតនៅថ្ងៃទី១២ខែតុលាឆ្នាំ១៩២១។

ក៖ ចា៎អ៊ំចាំទេថាគាត់កើតនៅខេត្តណា?

ខ៖ កាលគាត់កើតហ្នឹងហេ?

ក៖ ចា៎!!ទីកន្លែងកំណើតហា៎?

ខ៖ កំណើតគាត់នៅភូមិដំរីស្លាប់អូន ឃុំទ្រា ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។ហ្នឹងហើយ ជិតទន្លេបាទីហ្នឹងអូន។

ក៖ គាត់កើតចំឆ្នាំសត្វខ្មែរជាអ្វី?

ខ៖ អើគាត់ជ្រូក គាត់កុល។

ក៖ កុល!!

ខ៖ កុលហ្នឹងហើយ!!

ក៖ គាត់ស្លាប់ហើយ?

ខ៖ គាត់ទើបតែស្លាប់ឆ្នាំទៅហ្នឹង!!!ឆ្នាំ២០១៥។

ក៖ ២៩១៥!!

ខ៖ ថ្ងៃទី១៩ ខែមិនា។ស្លាប់នៅទួលទំពូង។

ក៖ ស្លាប់នៅទួលទំពូង!! តើមានការចងចាំអ្វីខ្លះជាមួយនឹងគាត់?

ខ៖ គាត់ប្រៀនប្រដៅអំម៉េចខ្លះដែរ?

ខ៖ អើគាត់ស្រលាញ់ខ្ញុំណាស់ដោយសារមានតែខ្ញុំម្នាក់គាត់ស្រលាញ់មែនទែនស្រលាញ់រហូតដល់គាត់មានចៅហើយ ស្រលាញ់ខ្ញុំជាងចៅជាងកូនទៅទៀតជាងចៅ ជាងចៅទួតទៅទៀតគាត់ស្រលាញ់ខ្ញុំខ្លាំងណាស់ សំរាប់ពេលដែលគាត់ស្លាប់ញ៉ុមស្ដាយគាត់មែនទែន គាត់កាលស្លាប់អាយុ៩៤ហា៎ ហ្នឹងហើយ៩៤ គាត់ស្លាប់ហ្នឹងគឺពេលខ្ញុំដឹកដៃគាត់ចុះពីលើផ្ទះដើម្បីមុជទឹកក្រោមផ្ទះគាត់ហូបបាយហើយភ្លាមៗហា៎!!!ហ្នឹងហើយ មុជទឹកហើយជិតហើយមែនទែនហើយ មុជទឹកហ្នឹងបន្ទប់ទឹងហ្នឹងស្រាប់គាត់តែទន់ដៃទន់ជើងម៉ង ទន់ដៃទន់ជើងគាត់ គាត់ជើងគាត់ដូចក្មេងចឹងហា៎ រវៃរវក់ហា៎ហើយទៅពេទ្យគេថាគាត់ដាច់សរសៃរឈាមខួរក្បាល រួចគាត់ស្លាប់នៅពេទ្យកាល់ម៉ែត ញ៉ុមស្រណោះគាត់តត្រង់ថា គាត់ គាត់អាយុប៉ុណ្ណឹងហើយណាស់អើយអ្នកខ្លះគេថាគាត់ចាស់ទុំ មិនមែនចាស់ធម្មតាទេណាស់ចាស់ដល់ទុំទៀតហា៎ ចាស់ទុំជ្រុសហា៎!!

ក៖ តើជីតាខាងម្ដាយឈ្មោះអ្វី?

ខ៖ អើគាត់ម៉ែន ឈ្មោះម៉ែន!!អ្នកម្ដាយខ្ញុំឈ្មោះម៉ែន សេម ជីតារបស់ខ្ញុំឈ្មោះម៉ែន។

កៈ កើតនៅថ្ងៃខែឆ្នាំ?

ខៈ អត់ អត់ចាំទេ។

គៈ នៅជំនាន់ណាដែរអ៊ំមានចាំជំនាន់ទេ?

ខៈ ជំនាន់សម្ដេចសីហានុ ហោជំនាន់មុនសម្ដេចសីហានុទៀតហ្នុ៎!!!

កៈ ប្រហែលជាគាត់កើតឆ្នាំ១៨០០ជាងឬ១៩០០ជាង។ ចាំទីកន្លែងកំណើតរបស់គាត់ទេអ៊ំ?

ខៈ អើមិនដឹងទេប្រហែលជាស្រុកកំណើតគាត់នៅម្ដុំដែលញ៉ុមនិយាយមិញហ្នឹង នៅស្រុកកណ្ដាលស្ទឹងហ្នឹងហើយមើលទៅ មានឯណាឆ្ងាយជាងហ្នឹងទេនៅខាងជើងវត្តកោះស្វៃក្រាំ។

កៈ ប៉ាកើតទាន់អត់?

ខៈ អើបើប៉ាកើតនៅថ្ងៃនោះ។

កៈ ចឹងកើតអត់ទាន់គាត់ទេអ៊ំហោ៎?

ខៈ អើម្ដាយ យាយអាយុចង់៣០ហើយបានបានប៉ាហ្នឹង!!ហើយមុនបានញ៉ុមគាត់សុំក្មួយម្នាក់ធ្វើកូនបាត់ហើយ គ្រាន់ថាគាត់គិតថាគាត់អត់កូនហា៎!!ដឹងនៅ? អើសុំបងជីដូនមួយញ៉ុមធ្វើកូនហើយឥឡូវគាត់ស្លាប់អស់មួយពូជហើយសម័យប៉ុល ពត សម្លាប់អស់រលីង កូនប៉ុន្មាននាក់សម្លាប់អស់ ស្លាប់ទាំងប្រពន្ធទាំងកូន។

កៈ ចឹងតាស្លាប់ហើយចឹងហ្នុ៎?

ខៈ ហ្នូស្លាប់យូរហើយអត់ទាន់ ប៉ាអត់ទាន់ផង។

កៈ បាទៗអត់មានការចងចាំពីគាត់ណាហី?

ខៈ អត់ អត់ទេ អត់ស្គាល់មុខគាត់ផងហ្នឹង។

កៈ ចុះខាងយាយវិញ?

ខៈ ខាងយាយក៏អត់ចាំដែរអត់ចាំទាំងអស់!!!

កៈ ចឹងសំរាប់តាខាងម្ដាយវិញ? ឈ្មោះអីគេវិញអ៊ំ?

ខៈ និយាយតាខាងម្ដាយឈ្មោះ ម៉ែនបើតាខាងប៉ាបានឈ្មោះអ៊ុំទេ !!ហ្នឹងតាខាងម្ដាយឈ្មោះម៉ែន។

កៈ ឈ្មោះម៉ែន ចឹងគាត់ស្លាប់គាត់អត់ដឹង?

ខៈ អត់ដឹង ញ៉ុមអត់ទាន់ទេញ៉ុមទូចណាស់!! រួចប៉ានៅតែភ្នំពេញហ្នឹង ហើយសំរាប់គាត់នៅតែស្រុកហើយសម័យ សម័យយើង សម័យលន់ នល់ យើងទៅស្រែបានយើងទៅស្រុកអត់បានទេហាំ!!ទៅអត់បានទេសម័យសង្គ្រាម ទាល់អាពតបែកអាពតហ្នឹង គៀតទៅបានទៅហ្នឹងបានយើងទៅ ទៅជួបគាត់បានមួយភ្លែតហ្នឹងហើយគាត់ស្លាប់ ប៉ាស្លាប់ឆ្នាំ៧៥ទៅ(១៩៧៥)ហ៊ឺ ហើយយើងមកភ្នំពេញវិញបានឪម៉ែស្លាប់ទៀត។

កៈ យាយខាងប៉ាឈ្មោះអី?

ខៈ អត់ អត់ស្គាល់ទេអូនអត់ស្គាល់ទេ។

កៈ ចឹងសំនួរថាតើឪពុកម្ដាយនឹងជីដូនជីតាធ្លាប់ទៅរស់នៅប្រទេសក្រៅដែរឬទេ?

ខៈ អត់ទេ អត់មានអត់ទេ។

កៈ តើរៀនដល់ថ្នាក់ទីប៉ុន្មាន?

ខៈ អើកាលហ្នឹងបានប្រលងបាក់អង វាក្លាយព្រីមីញែហាំ!!!ថ្នាក់ទី១ពីដើមហាំ!!

កៈ ចឹងតើរៀននៅសាលាបឋមសិក្សាអ្វីដែរ?

ខៈ កាលហ្នឹងបឋមសិក្សាព្រះកែវមរកត ឥឡូវគេដាក់សាលាវិទ្យាល័យទួលទំពូងហ្នឹងឯង ពីដើមមកគេដាក់បឋមសិក្សាទេពីដើមមកព្រីម៉ែទេហ្នឹងណាស់តែឥឡូវវាចូលលីសេហើយរាល់ថ្ងៃ ហ្នឹង គឺសាលាទួលទំពូងរាល់ថ្ងៃ វិទ្យាល័យទួលទំពូងរាល់ថ្ងៃហ្នឹង។

កៈ រៀននៅអនុវិទ្យាល័យអ្វីដែរ?

ខៈ កាលហ្នឹងរៀននៅវិទ្យាល័យក្បាលថ្នល់ដំបូង ក្បាលថ្នល់ឥឡូវគេដាក់បឹងត្របែករាល់ថ្ងៃហ្នឹងដល់ហើយញ៉ុមរៀនបាន៣ឆ្នាំត្រង់ស្វែរទៅពញាយ៉ាតពញាយ៉ាតគេហៅដាក់គុកទួលស្លែង សព្វថ្ងៃ។

កៈ បាទ!!

ខៈ ឈ្មោះ ពញាយ៉ាតពីដើម។

កៈ ចាំចឹងសាលាអ៊ំកន្លែងគុកទួលស្លែងហ្នឹង?

ខ៖ ហ្នឹងហើយ អាគុកទួលស្លែងអាបូនសំណាង់ អាបូនអាគារហ្នឹង ហ្នឹងហើយគឺជាគុកទួលស្លែងចំតួអង្គហើយ។

ក៖ ចា៎!!

ខ៖ តែឆ្នាំ៧៩(១៩៧៩)ហ្នឹងគេមិនចូលពីមុខតែចូលពីក្រោយ ចូល សាលាទួលស្លែងហា៎!!!!

ក៖ ចា៎!!

ខ៖ ចឹងបានគេដាក់គុកទួលស្លែងហ្នឹង ទួលស្លែងគឺជាសាលា
បឋមសិក្សាឈ្មោះទួលស្លែង!!ដឹងនៅ?

ក៖ ចា៎!!

ខ៖ ទួលស្លែងគេអើសម័យលន់ នល់គេដាក់ទួ លស្លែង
ហើយអាពញាយ៉ាតហ្នឹងគេដាក់ទួលស្វាយព្រៃ ណាស់!!!សម័យលន់ នល់ហា៎!!ហ្នឹង
ហើយញ៉ុមនិយាយពញាយ៉ាតញ៉ុមនិយាយសម័យសីហានុទេ!!ជំនាន់សម្តេចសីហានុគុកទួល
ស្លែងឈ្មោះឥន្ទ្ររទេវី សាលាឥន្ទ្ររទេវីហា៎ ហ្នឹងហើយ !!ហើយដល់ពេលលន់ នល់គេដាក់ទួល
ស្លែង ហើយអាលីសេជាគុកហ្នឹងប្តូរឈ្មោះដាក់វិទ្យាល័យទួលស្វាយព្រៃវិញ ដឹងនៅ?

ក៖ ចា៎!!

ខ៖ ហើយវិទ្យាល័យឥន្ទ្ររទេវីនៅទួលគោកហ្នឹងផ្សេងហ្នឹងណាស់!!

ក៖ ចា៎!!

ខ៖ ហ្នឹងហើយ កុំអោយច្រលំគ្នា។

ក៖ ចា៎!!ហើយរៀននៅវិទ្យាល័យអីដែរ?

ខ៖ ហ្នឹងហើយវិទ្យាល័យឈ្មោះហ្នឹង ពញាយ៉ាតហ្នឹងវិទ្យាល័យទួលស្វាយព្រៃហ្នឹងឥឡូវគេ
ហៅគុកទួលស្លែងហ្នឹង។

ក៖ ហើយសកលវិទ្យាល័យ?

ខ៖ អត់បាន អត់បានចូលរៀនទេដោយសារកាលហ្នឹងយើងវាមិនទាន់បានចូលសកល
វិទ្យាល័យទេ ទាល់តែយើងចប់បាក់ឌុបបានយើងចូលសកលវិទ្យាល័យ សកលវិទ្យាល័យនឹង
មហាវិទ្យាល័យ!!

ក៖ តើក្តីនៅពេលអនាគតចង់ក្លាយជាអ្វី?

ក៖ ពេលរៀនហ្នឹងអ៊ំ?

ខ៖ ពេលរៀនហ្នឹងហោ៎?

ក៖ ចា៎!!

ខ៖ ចង់ក្លាយជាគ្រូបង្រៀន។

ក៖ ហើយក្តីស្រម៉ៃក្លាយជាការពិតទេ?

ខ៖ ឥឡូវជាការពិតតិចៗដែរហើយបានមកធ្វើកិច្ចការនៅព្រះវិហារ។

ក៖ ឮធ្លាប់កាលមុនធ្លាប់បង្រៀនបារាំង ធ្លាប់ធ្វើជាគ្រូបង្រៀនបារាំងទេ?

ខ៖ កាលហ្នឹងញ៉ុមពូកែខាងបារាំងប៉ុន្តែដល់ពេលសម័យប៉ុល ពតត្រលប់មកវិញមកវាទៅជាចូលត្រឡោកអស់ទៅដោយសារយើងគិតគូររឿងងាប់រស់ហ្នឹងហា៎!!នឹកឃើញ នឹកឃើញថានៅទីនេះវាខ្ជិលចាស់មែនទែនហើយ។

ក៖ ចុះកាលពីមុនចេះសរសេរចេះអានចេះបារាំង?

ខ៖ ចេះ ចេះទាំងតែងសេចក្តីកាប៊ីឡែរ ចេះកុំប៉ែរស្យុងចេះមួយចប់ចេះតែងសេចក្តីតែងអីមួយចប់កាលហ្នឹង។

ក៖ ចឹងឥឡូវនៅចេះចាំភាសារបារាំងទេ?

ខ៖ ឥឡូវបើយកមកអាន អានដឹងតែគ្រាន់តែយកមកបកប្រែវាបាត់ បាត់ច្រើនណាស់បាត់ច្រើនភាគរយណាស់។

ក៖ តែអានបាន?

ខ៖ ហ៊ឺអាន អានបានៗ តែយើងខានអាន ខានមើលហ្នឹង ចូលចង់ជាង៣០ ៤០ហើយតែបើសិនជាមកមើលអាចមើលបាន។

ក៖ តើធ្លាប់ធ្វើស្រែចំការឬទេ?

ខ៖ សម័យប៉ុល ពត ស្ទាត់ជំនាញ ក្លាយជាជនគំរូរទៀត!!

ក៖ ឬក្រុមគ្រួសារជាអ្នករកស៊ី?

ខ៖ អើប៉ា កាលតាអូនឯងហ្នឹង កាលគាត់នៅរស់ គាត់ធ្វើការនៅស្ថានទូតអាមេរិចកាំង!!ហើយម៉ែគាត់រកស៊ី ហើយគាត់មានដីស្រែនៅទន្លេបាទីច្រើនណាស់ គាត់ប្រវាស់អោយគេហាំ គាត់តិចទៅស្រែៗគាត់ទៅស្រែគាត់យកអីទៅលក់នៅស្រែហ្នឹងហាំ!!ហើយមកវិញគាត់កិនអង្ករកិនស្រូវមកផ្ទះ !!!ដឹងនៅពីដើម?ពីដើមគិតទៅស្រួលមែនទែន!!

ក៖ កូនអ្នកមាន!!

ខ៖ អើ!!មានតែម្នាក់ឯង ឪពុកម្ដាយស្រលាញ់ណាស់ហើយញ៉ុមធ្វើផ្ទះជូលអោយគេទៀត!!ផ្ទះល្វែងជូលអោយគេហាំ!!

ក៖ ចាំ!!!

ខ៖ ហ្នឹងហើយ ហើយអ្នកណាគេក៏ខ្លាចញ៉ុមដែរ!!! ប្រសិនបើ
ញ៉ុមរើកូនអ្នកដែលជូលផ្ទះទាំងប៉ុន្មានអត់ដែលមានអ្នកណាគេថាអោយញ៉ុមទេ ម៉ែឪខ្ញុំស្រលាញ់ខ្ញុំខ្លាំងណាស់។

ក៖ ខូចទៀត!!!

ខ៖ ខូចទៀត!!ខូចហើយខិលទៀត!!

ក៖ តើរៀបការនៅថ្ងៃខែឆ្នាំណា?

ខ៖ រៀបការនេះគឺការប្រពន្ធមុន មុនដែលស្លាប់បាត់ហ្នឹងគឺរៀប ពីអាពតរៀបអោយទេកាលហ្នឹងហាំ!!ដឹងនៅ??

ក៖ ចាំ!!!

ខ៖ អាពតរៀបអោយទេ!!

ក៖ ពីឆ្នាំណាអ៊ំ?

ខ៖ កាលហ្នឹងដូចជាចុងឆ្នាំ៧៦(១៩៧៦)។

ក៖ បានកូនប៉ុន្មាននាក់ដែរ?

ខ៖ កូន៦នាក់។

ក៖ ចុះប្រពន្ធក្រោយការនៅពេលណា?

ខ៖ ឆ្នាំ៨៦(១៩៨៦)។នៅសង្កាត់ស្រះចក អូនស្គាល់សង្កាត់ស្រះចកអត់?

ក៖ ស្គាល់។

ខ៖ ស្រះចកយើងនៅខាងត្បូវស្ថានជ្រោយចង្វាបន្តិចហាំ!!!

ក៖ ចាំ!!

ខ៖ នៅអាកន្លែងពេទ្យ កាល់ម៉ែតហាំ!!!

ក៖ សំនួរមួយទៀតតើរៀបការត្រូវឪពុកម្ដាយជាអ្នកបង្ខំឬក៏ស្រលាញ់គ្នាដោយចិត្តខ្លួនឯង?

ខ៖ គឺអាចិត្តនោះស្រឡាញ់ ស្រលាញ់ហើយគឺអាណាព្យាបាលរៀបអោយទៅ កាលហ្នឹងគាត់នៅម្ដាយ ខ្ញុំក៏នៅម្ដាយគាត់ក៏នៅម្ដាយដែរ!!ដឹងនៅ?

ក៖ ចាំ!!!

ខ៖ ឥឡូវស្លាប់ទាំងម្ដាយគាត់ស្លា ប់ទាំងម្ដាយញ៉ុមក៏ស្លាប់ហើយបងប្អូនគេទទួលស្គាល់ទាំងអស់គ្នា។

ក៖ បាទ!!!តើជួបគេជាមួយភរិយាដំបូងនៅពេលណា?

ខ៖ ជួបមួយណាៗ?

ក៖ ឥឡូវនិយាយពីដំបូងសិន!!!

ខ៖ អាពីដំបូងហោ?

ក៖ ចាំ!!!

ខ៖ ជួបសម័យប៉ុល ពត។

ក៖ ចឹងអាក្រោយ?

ខ៖ អាក្រោយជួបនៅសម័យយើងហ៊ុន សែន សម័យរដ្ឋកម្ពុជា។

ក៖ រដ្ឋកម្ពុជា!!

ក៖ ចុះជួបគេដំបូងនៅឯណាអ៊ំ?លើកដំបូង ហើយថីបានស្រលាញ់។

ខ៖ នៅទួលទំពួង។

កះ តើរៀបការមានបណ្ដាការទេ?

ខះ មាន មានគ្រប់បែបយ៉ាងទាំងអស់។

កះ ចាំហ្នឹងហើយ!!

កះ តើជីវិតពីអតីតកាលខុសគ្នានឹងបច្ចុប្បន្នយ៉ាងម៉េចដែរ?

ខះ អើខុសគ្នាច្រើនណាស់ ក្មេងពីសង្គមហើយឥឡូវខុសគ្នាច្រើនណាស់ខុសគ្នាមែនទែន ដោយសារញ៉ុមពីមុន ញ៉ុមក្មេង ពីក្មេងហើយកាលហ្នឹងអត់មានគិតគូរវែងឆ្ងាយច្រើនហើយយើងនៅក្នុងការគ្រប់គ្រងរបស់ឪពុកម្ដាយ!!ឪពុកម្ដាយយើងមានទៀតអត់មានបញ្ហាអីសោះ!!ដឹងនៅ?

កះ ចាំ!!!

ខះ ដល់ឥឡូវយើងក្លាយជាមនុស្សចាស់ យើងអាចផ្ដត់ផ្គង់ដល់កូនដល់ចៅទៀតម្ល៉ោះហើយខុសគ្នា ទោះយើងសប្បាយក៏អត់សប្បាយដូចមុន។

កះ ម្ហូបចូលចិត្តម្ហូបអី?

ខះ ញ៉ុមចូលចិត្តស្ងោរ។

កះ ស្ងោរ?

ខះ ហ្នឹងហើយ។

កះ ចេះធ្វើម្ហូបទេ?

ខះ ស្ទាត់ជំនាញ ខ្ញុំចេះតាំងពីរក្មេងដោយសារខ្ញុំម្នាក់ឯង ម្ដាយញ៉ុមឧស្សាហ៍មកស្រែ ប៉ាញ៉ុមធ្វើការចឹងទៅ ញ៉ុមចេះអាំងចេះចៀនចេះស្ងោរ ច្បាស់ជាងគេអាំងចៀនស្ងោរហ្នឹងចូលចិត្តណាស់!!! លៀសក៏ស្ងោរដែរលៀស!!!

កះ ធ្លាប់ធ្វើការនៅអាពោងការពោងអី!!!

ខះ ចេះធ្វើម្ហូបការដែរ កាលឆ្នាំ៨០ប៉ុន្មានទេ ៨០ក្រាស់។

កះ រៀនធ្វើម្ហូបពីអ្នកណាគេដែរ?

ខ៖ អត់មានរៀនណាផង យើងធ្វើចុងភៅម្ហូបការហ្នឹងយើងរៀនហ្នឹងយើងរៀនតាមគ្នាហ្នឹង!! កាលមុនហ្នឹងយើងរត់តុការហ្នឹង!!យើងរត់តុការហើយអាចង្រ្កានបាយឆ្នាំងហ្នឹងយើងចេះមើលគេឯងយើងចេះខ្លះៗទៅណាស់!!

ក៖ ពេលទំនេរចូលចិត្តធ្វើអ្វី?

ខ៖ ចូលចិត្តណាស់រឿងម៉ាញ៉េ ចូលចិត្តណាស់រឿងចំរៀងចូលចិត្តមែនទែន!!ហើយចូលចិត្តរហូតដល់ចេះតែងខ្លួនឯងទៀត!!

ក៖ អ៊ូឡូយទៀត!!

ខ៖ សូម្បីតែខ្ញុំតែងមិនបាច់សរសេរទេ បើសិនជាចិត្តថាចង់តែងហើយ ញ៉ុមដើរមួយភ្លេតញ៉ុមតែងបានមួយបទទៅហើយ។

ក៖ អ៊ំចេះច្រៀងទេ?

ខ៖ អ្ហូច្រៀងស្ទាត់ណាស់!!

ក៖ ច្រៀងមួយបទមក!!

ខ៖ អត់ច្រៀងអោយឮទេ។

ក៖ ទុកច្រៀងអោយប្រពន្ធស្តាប់!!

ក៖ ចូលចិត្តកំសាន្តនៅទីកន្លែងណា?

ខ៖ ចូលចិត្តកន្លែលដែលទេសភាព អត់ចូលចិត្តទេកណ្តាលទីក្រុងអួរអាប់អត់ចូលចិត្តទេ ចូលចិត្តទេសភាពតាមស្រុកស្រែចំការ តាមវាល តាមស្រែអីតាមព្រៃភ្នំអីចូលចិត្តណាស់ ចូលចិត្តមែនទែន!!កាលពីដើមស្រុកកំណើតនៅភ្នំពេញវាអ៊ូរអររហូតហា៎!! អ៊ូអររហូតដល់សម័យ លន់ នល់ នៅតែអ៊ូរអរទៀត សម័យអាពតប្លែកដែរឃើញល្ហែរល្ហែរហា៎ ប៉ុន្តែគ្រាន់តែគេបង្ខំខ្លាំងពេក

ក៖ ចូលចិត្តល្បែងប្រជាប្រិយអ្វីដែរ?

ខ៖ ល្បែងគឺចូលចិត្តតែមើលគេ តែលេងខ្លួនឯងងអត់សូវចូលចិត្តប៉ុន្មានផង បើមើលគេសប្បាយ។

ក៖ ចូលចិត្តចំរៀងបែបណា៎ដែរ?

ខ៖ ពីមុនមកចូលចិត្តសង់ទីម៉ង់ មនោសញ្ចេតនាទេតែឥឡូវចាស់ទៅចូលចិត្តទាំងអស់!!

ក៖ ចូលចិត្តញាក់!!!

ខ៖ ចូលចិត្តទាំងអស់អ្នកតែង អ្នកនិពន្ធអោយពិរោះទាំងអស់ចឹងនៅក្នុងសេរីពីដើមៗវុលវាមកវិញជាចាប់ឆាយលាយម៉ងហាំ!! មិនមែនថាស្លូតរហូត កាចរហូត ញាក់រហូតទេ គេមានលាយគេមានលាយសារ៉ាន់ ក្បាច់ លាំងលាវអីចឹងទៅណាស់!!គេមានសង់ទីម៉ង ស្លូវ!!ស៊ីសអីចឹងទៅកុំអោយយើងសាំ ញុំមចូលចិត្តទាំងអស់ឥឡូវហ្នឹង។

ក៖ ហើយតើចេះលេងឧបករណ៍តន្ត្រីដែរឬទេ?

ខ៖ អត់ចេះទេ ចេះតែច្រៀង ច្រៀងស្ទាត់។

ក៖ ចេះចាក់បទចំរៀង!!

ខ៖ ហ្នំបើចាក់ បើថតវិញចេះ ចេះសារទៀតហ្នំ!! អោយលឿនសារអោយយឺត ហ្វេងយឺតពេកធ្វើអោយល្មមម៉ាដូចច្រៀងមែនទែនចឹង ញុំមថត ថតចំរៀងពីដើមហាំ!!

ក៖ ចាំ!!

ខ៖ ញុំមថតបាន ប៉ុន្មានឆ្នាំដែរ
ថតកាលហ្នឹងតែញុំមជក់ថតហើយឈរតាំងពីក្បាលព្រលប់ទល់ភ្លឺហ្នំ!!មួយយប់ហ្នឹងអត់មានដេកទេ។

ក៖ ចឹងសំនួរនេះរាងប្រហែលជាឆ្លើយរាងវែងហើយ សូមប្រាប់ញុំមពីជីវិតរបស់ប៉ានៅជំនាន់ប៉ុល ពតបានទេ?

ខ៖ បាន បាន!!

ក៖ ម៉េចខ្លះអុំរៀបរាប់អោយអស់មកអុំ!!!

ខ៖ ហ្នំច្រើន ដោយសារអាពតពិបាកខ្លាំងហើយដោយសាររំលឹកអនុស្សាវរីយ៍នៅសម័យ លន់នល់ហើយដែលយើងកើតមកបែកសម័យ៧៥(១៩៧៥)ហ្នឹងធ្វើអោយយើងស្រណោះដូចថាស្អែកឡើងយើងងាប់ហាំ!! ដល់នឹកឃើញស្អែកងាប់ចឹង ដឹងនៅ?ដល់នឹកឃើញថាស្អែកងាប់ចឹងយើងនៅតែងមួយឆាកៗ មួយឆាកៗ មួយឆ្នាំៗ មួយបទៗហាំ!! យល់ទេអូន?

ក៖ ចាំ!!

ខ៖ មួ យបទៗហ្នឹងមួយឆាកៗហើយណាស់!!ដោយសារយើងពី០ឆ្នាំដល់អាយុ២០ឆ្នាំ ៧៥(១៩៧៥) ហ្នឹងយើងអាយុ២០ឆ្នាំហាំ!!

ក៖ ចាំ!!

ខ៖ វាឆ្លងកាត់ជីវិតច្រើនណាស់ ដឹងនៅ?

ក៖ ចាំ!!

ខ៖ ដូចកា លពីនៅទូចកុមារ ធំដឹងក្ដីមកចូលរៀន ចូលរៀនដំបូងតាំងពីចូលរៀនដំបូងអត់ដឹងអីទេ ដល់ ចាប់រៀនតាំងពីទូចបានយើងចេះរៀនស្រលាញ់ មើលគេមើលអីស្អាតបាតចឹងហាំ!!ម្ល៉ោះ ហើយយើងតែងរហូត មួយវគ្គៗហ្នឹង ញ៉ុមតែងជិត១០០បទម៉ាទៅហ្នឹង តែអត់មានសរសេរអី ទេ!!

ក៖ ចាំ!!

ខ៖ តែងក្នុងខួរក្បាលទាំងអស់ តែហ៊ានតែសរសេរគេយកទៅសម្លាប់ចោលឥឡូ វលហើយអត់បានទេ។

ក៖ ចុះឥឡូវអ៊ំសរសេរបានទេ?

ខ៖ ខ្ញុំយកមករំលឹកសរសេរម៉ាកំនរហ្នឹងតែវាបាត់អាក្រដាសៀវភៅហ្នឹងឥឡូវនេះ។

ក៖ អ៊ំគួរតែតែងមួយហ្នឹងឡើងហាំដោយសារមួយហ្នឹងល្អហើយប្រហែល!!!

ខ៖ វាតែងបានហើយប៉ុន្តែត្រឹម៥០ភាគរយបានមកវិញទេអូន!!ដោយសារអា៥០ភាគរយបាត់ ឆឹងម៉ង។

ក៖ ចាំ!!

ណ:គ្រាន់តែគេគួសអាកាំងទៅស៊ីបាយហ្នឹងញ៉ុមតែងបានបាត់ គ្រាន់តែឃ្វាល គោហ្នឹងញ៉ុមតែងបានបាត់ ហើយថ្ងៃហ្នឹង១០ថ្ងៃគេអោយទៅផ្ទះម្ដងយើងហ្នឹង ហ៊ីវណ្ណះឯងទៅ កាប់អុសទៅ កាប់អុសនៅព្រៃករកា អូនឯងស្គាល់ព្រៃករកាអត់?

ក៖ ស្គាល់!!

ខ៖ ហ្នឹង ព្រៃករកា កាលហ្នឹងខែភ្លៀងញ៉ុមទៅកាប់ កាប់បានមួយរទេះមែន!!
ដល់ល្ងាចឡើងហ៊ីម៉ោង៤ ម៉ោង៥ មិត្តឯងមិនបាច់ទៅទេ អោយអានេះទៅវិញទៅ
ញ៉ុមអត់បានទៅទេនឹកឃើញថាបានទៅជួប
អ្នកផ្ទះបានសប្បាយចិត្តហាំ!!បានជួបហាំជួបប្រពន្ធជួបកូនសប្បាយអត់បានទៅវិញ !!

ក៖ ចាំ!!

ខ៖ ញ៉ុមតែងបានទាំងអស់អោយតែអ្វីដែលធ្វើអោយចាប់អារម្មណ៍ញ៉ុមតែងបានទាំងអស់។

ក៖ ល្អមែនទែនអ៊ំ!!

ខ៖ ហ្នឹងហើយ!!

ក៖ ការហូបចុកនៅសម័យប៉ុល ពតម៉េចដែរ?

ខ៖ ហ៎ថាពិបាក ពិបាកណាស់ ប៉ុន្តែដោយសារខ្ញុំមនុស្សត្រង់ដឹងហេ!!មនុស្សត្រង់អាពតស្រលាញ់ដែរឃើញមនុស្សត្រង់ចឹងហាំ!!

គ:ចាំ!!

ណ:វាពិសោធន៍ញ៉ុមអស់ចិត្តអស់ចង់ហើយ សូម្បី
តែទៅដល់ដំបូងកាលឆ្នាំ៧៦(១៩៧៦)វាថាហ៊ីមិត្តណាក់ចុះមកដកថ្លឹង ដកថ្លឹងអាយើងនៅទន្លេបាទីកន្លែងវត្តកោះស្វាក្រំ អូនឯងស្គាល់អត់?

ក៖ ស្គាល់ ស្គាល់!!!

ណ:កន្លែងវត្តកោះស្វាក្រំមានស្ពានមួយ មិត្តណាក់ចូលមកចុះមក ហ៉ចុះម៉េចអត់ចេះហែលទឹកហោចុះមកអត់អីទេ រួចមិនមែនមានតែខ្ញុំម្នាក់ទេណាស់ប្រុសៗប្អូនដប់ម្ភៃនាក់ហាំគេលោតផ្លូងៗ គ្រាន់តែញ៉ុមលោតភ្លាមគេស្រង់ខ្ញុំមកវិញភ្លាម គេចង់ដឹងថាយើងហ៊ានមិនហ៊ានណាស់ដឹងនៅ!!!គេដឹងថាយើងលង់ឬមិនលង់ហាំ!!

ក៖ ចាំ!!

ខ៖ ដល់យើងលង់មែន គេពិសោធន៍ញ៉ុម ច្រើនណាស់តាំងពីកាប់ដំនាំដាំដំនាំ
កាប់ព្រៃអីហ្នឹងគេលបមើលយើងទាំងអស់ គេលបមើល
ក្នុងកំពតព្រៃហាំ!!គេដឹងថាអើយញ៉ុមធ្វើការខ្លាំងណាស់ ដឹងថីគេពិសោធន៍ញ៉ុមខ្លាំងចឹង?
ដោយសារខ្ញុំចិត្ត ថាធ្វើអីញ៉ុមធ្វើហើយ គឺស្រីប្អូន ដប់អ្នក ហើយមានប្រុសក្មេងពីរ បីនាក់ឈរ

មើលញ៉ុមអ្នកកាប់ កាប់ៗដីកំណ្ទកចឹងហើយ ដល់ហើយខ្ញុំមិនឈប់ អោយគេរែកណាស់!!គ ចា៎!!ណា ញ៉ុមអង្គុយ អង្គុយចឹងហ៎!! ដល់អង្គុយភ្លាមមិត្តពួកអាធំៗវាមកហា៎!!ប្រធានសហករណ៍ ប្រធានក្រុម ប្រធានអីគេមកដើរចូល ដើរចូលប្រធានខ្ញុំឯណោះ ជាប់ខ្ញុំហ៊ីថា នោះគេមកហើយ នោះគេធំៗគេមកហើយ ងើបធ្វើការវិញ ហ៉េសែងដីអស់សិនចាំធ្វើ គេដឹងបាត់ហើយហ៉េ!!ដឹង ថាយើងវាត្រង់បាត់ហើយហ្នឹង ថាសែងដីអោយអស់សិនចាំញ៉ុមធ្វើតាមក្រោយ ចឹងញ៉ុមអត់ធ្វើ ទេ ហ្អែងមក មកទៅញ៉ុមអង្គុយធម្មតា គ្រាន់តែគេសែងដីជិតអស់ញ៉ុមចាប់ផ្តើមកាប់ទៀត តាមការពិតវាមើលយើងហើយ ហើយហា៎!!គ:ចា៎!! ខ៖ អាអ្នកហ្នឹងវាមើលយើងអស់ចិត្តហើយ សូម្បីតែខ្ញុំព្យួរស្រែក្នុងទឹកហា៎!!ក៏គេដើរតាមពីក្រោយខ្ញុំមើលដែរគេមិនដើរពីក្រោយយើងជាប់ ទេ រំលងប្រហែលជា ៤ ៥ម៉ែត្រគេដើរ គេដើរស្ទាប់ហា៎!!! ស្ទាប់ចុងនង្គ័លហ្នឹងហា៎!!ទីបំផុតមក គេដាក់ខ្ញុំជាគំរូហា៎!!១៧មេសាគំរូ ដោយសារផ្ទះខ្ញុំក៏ខ្ញុំដាំដែរ ផ្ទះនៅហ្នឹងហា៎នៅកន្លែងវត្តកោះ ស្វ៊ូក្រំហ្នឹងហា៎!!

ក៖ ចា៎!!

ខ៖ ដាំតាំងពីស្លឹកគ្រៃដាំតាំងពីននោង ដាំតាំងពីដើមចេក គ្រប់បែបយ៉ា ង ដាំអំពៅ ថាសហករណ៍២ ៣ ថ្ងៃទៅគាស់មួយគុម្ព ២ ៣ថ្ងៃទៅបេះននោង ដល់ចឹងហើយគេ លើកញ៉ុមជាគំរូហា៎!!

ក៖ ហើយគេអោយអំហូបទេ?

ខ៖ គេអត់ថាអីទេ ហូបហូបទៅដោយសារគេពិសោធន៍យើងអស់ចិត្តហើយម៉្លោះហើយគេអត់ ហ៊ានជាមួយយើងខ្លាំងទេណាស់!!ដែលយើងមនុស្សត្រង់ហា៎ដឹងនៅ?ក៖ ចា៎!!

ក៖ ចឹងបានញ៉ាំបានអីហូបចុកគ្រប់គ្រាន់?

ខ៖ បានខ្លះៗដែរអត់អីទេ!!!

ក៖ ចា៎!!

ខ៖ តែមុននឹងបានហ្នឹងគេពិសោធន៍យើងអស់ចិត្តអស់ចង់ ហើយ។

ក៖ ចឹងអាមុនហ្នឹងបានហ្នឹងតាស្លាប់បាត់ហើយចឹងហ្ន៎?

ខ៖ តាស្លាប់បាត់ហើយ តាស្លាប់ថ្ងៃ២វិច្ឆិកា១៩៧៥ ដល់សាលកើតថ្ងៃ១៥វិច្ឆិកា១៩៧៦ អាសាលបងគេបង្អស់ហ្នឹង។

កៈ តើបានរួចខ្លួនពីសម័យប៉ុល ពតមានអារម្មណ៍យ៉ាងណាដែរ?

ខៈ ហ្វ៎កាលហ្នឹងពេលណាដែលគេហៅខ្វះការដ្ឋាន ក្នុងផ្លូវជាតិលេខ២ ស្គាល់ផ្លូវជាតិលេខ៣ទេគន្ធា ស្គាល់ទេ?

កៈ ចាំ!!

ខៈ អាផ្លូវពីភ្នំពេញទៅស្រុកយើងហ្នឹងហាំ!! អាផ្លូវកៅស៊ូអាផ្លូវជាតិលេខ២ដឹងនៅ?ពីដើមអ្នកណាបានឆ្លងថ្នល់ហ្នឹងសឹងតែថើបថ្នល់កៅស៊ូទៀតណ្ហ៎!! ហ៊ីបានថ្នល់កៅស៊ូហើយលោកអើយ  បានថ្នល់កៅស៊ូជាខ្សែមួយខ្សែរយៈទៅដល់ទីក្រុងភ្នំពេញដឹងនៅ?

កៈ ចាំ!!

ខៈ ព្រោះកើតមក យើងកើតមកយើងឃើញថ្នល់កៅស៊ូរហូត ឃើញតែថ្នល់កៅស៊ូរហូត ទេដល់ពេលប៉ុល ពតយើងបាត់ថ្នល់កៅស៊ូដោយសារអាស្រុកនៅខាងហ្នឹងវាចូលដល់៧ ៨គីឡូហាំ!!ពីផ្លូវជាតិទៅហាំ!!

កៈ ចាំ!!

ខៈ ដល់ពេលយើងបានមកដល់ផ្លូវជាតិយើងសប្បាយណាស់បានស្គាល់ភ្នំពេញវិញហើយបានស្គាល់ផ្លូវកៅស៊ូហើយរងចាំហើយញ៉ុមតែងទៀតតែងអាបទភ្នំពេញសំលឹងមើលមេឃ មេឃខ្ពស់សែនឆ្ងាយធ្វើអោយអាល័យដល់គេហដ្ឋានផ្ទះធ្លាប់រស់នៅផ្តល់ក្តីសុខសាន្តមិនគួរឃ្លាតឋានពីរូបអ្នកហើយហ្នឹងណាស់!!គឺភ្នំពេញហ្នឹងឯងដូច្នេះបានថាមកភ្នំពេញគឺអរសប្បាយណាស់!! គ្មានអីសប្បាយជាងភ្នំពេញទៀត។

កៈ តើមានសល់សាច់ញាតិណាខ្លះក្រោយរបបប៉ុល ពតហ្នឹង?

ខៈ មាន មាន មានសម័យគឺនៅសល់ នៅសល់ជីដូនមួយ ប៉ុន្តែគឺជីដូនមួយគឺដូច ដូចអើមេឃហើយផ្កាយដោយសារគេឆ្ងាយ!!

កៈ ឆ្ងាយ!!

ខៈ គេឆ្ងាយពីយើងចិត្តខុសពីយើងនិយាយអោយ សាមញ្ញទៅណាស់ចឹងគេ គេមានផ្កាយ២ផ្កាយ៣មហាផ្ទៃណោះ!!

កៈ តើបន្ទាប់ពីរបបប៉ុល ពតប្រកបមុខរបរអ្វីចិញ្ចឹមជីវិត?

ខ៖ ហ្នឹងហើយខ្ញុំអើរត់រម៉ក់ ធ្វើការដែរ ធ្វើការវាប្រាក់ខែតិចពេក!!

ក៖ ពីការជាអាមេប៉ុស្តិ៍នៅ!!!

ខ៖ ញ៉ុមធ្វើការ២ ៣ កន្លែងហ្នំ ធ្វើការចាញ់រត់រម៉ក់ រត់អាម៉ក់បានលុយច្រើនជាង។

ក៖ ពេលប៉ាឯងធ្វើការមេប៉ុស្តិ៍នៅផ្សារដើមថ្កូវមែន?

ខ៖ មែនទេ ធ្វើការ ធ្វើការនៅក្រសួងកសិកម្មរុក្ខាប្រមាញ់ហ្នំ!!!

ក៖ ហ្នំ!!

ណៈកសិកម្មហ្នឹងកសិ កម្មខាងព្រៃ ហើយខាងព្រៃហ៊ឹងឯងនឹកឃើញម៉ែ
នឹកឃើញថាគាត់មានខ្ញុំមួយមានតែកូនមួយ
ហើយកាលជំនាន់ហ្នឹងខ្មែរក្រហមច្រើនណាស់!!បើទៅអត់បានអាយុវែងទេ សុខចិត្តឈប់ ឥឡូវគេយកឈ្មោះញ៉ុមទល់រាល់ថ្ងៃហ្នឹង អ៊ុំ វណ្ណៈ នៅរាល់ថ្ងៃហ្នឹងនៅក្រសួងរុក្ខាប្រមាញ់ គេជិះឡានហ្នំផ្ទះគេឡាន ៩ ១០ ហើយឈ្មោះខ្ញុំមែនទែន ខ្ញុំនេះសោះ!!

ក៖ តើអ្វីដែលចងចាំជាងគេនៅក្នុងជីវិត?អ៊ំចាំអ្វីជាងគេ?

ខ៖ ចាំជាងគេគឺទៅអាកន្លែងប៉ុល ពតហ្នឹងហើយបីសងាប់បីសរស់ដោយសារយើងអត់សង្ឃឹមថាអត់បានរស់ផង!!ដេករហូត ដេកការដ្ឋានបន់អោយពស់ចឹកងាប់វិញ ញ៉ុមនិយាយជំនាន់ហ្នឹងស្រម៉ៃឃើញតាំងពីគុយទាវ ស្រម៉ៃឃើញតាំងពីនំប៉ុង។

ក៖ ស្រម៉ៃរហូតអ៊ំ?

ខ៖ ស្រម៉ៃសព្វគ្រប់បែបយ៉ាង ស្រម៉ៃ!!

ក៖ ចាំ!!

ខ៖ ស្រម៉ៃបានតែស្រម៉ៃទេ។

ក៖ តើក្រោយពីរៀបការមានកូនប៉ុន្មាននាក់?កូនសរុបទាំងអស់ណាស់អ៊ំ?

ខ៖ អើកូនសរុបទាំងអស់ហោ?

ក៖ ចាំ!!

ខ៖ កូនសរុបទាំងអស់១០នាក់។

កៈ ឈ្មោះអីគេខ្លះ?

ខៈ ហ្ហ៎ ឈ្មោះច្រើនណាស់!!!

កៈ អ៊ំចាំទេរៀបរាប់!!

ខៈ ចាំទាំងអស់ហ្នឹង!!រៀបរាប់ពីលើមកទាំងអស់ម៉ងទៅណាស់!!

កៈ ចា៎!!

ខៈ អាបងបង្អស់ម៉ង អ៊ុំ កុសល អ៊ុំ មុនី អ៊ុំ ខេមា អ៊ុំវិច្ឆិកា អ៊ុំ សុភាព អ៊ុំ សំណាង ។

កៈ ចា៎!!

ខៈ បន្ទាប់មក អ៊ុំ វណ្ណា អ៊ុំ ប្រសិទ្ធ អ៊ុំ រស្មី អ៊ុំ លីឆេង។

កៈ ចា៎!!!

កៈ តើប្រពន្ធឈ្មោះអ្វី?

ខៈ ឃឹម គឹមហាក់។

កៈ ចុះប្រពន្ធពេលមុន?

ខៈ អើឈ្មោះ ធី ផាន់នី។

កៈ តើគាត់មានចរិកបែបណា?

ខៈ សួរពីណាគេ?

កៈ ទី១សិនអ៊ំ។

ខៈ អើគាត់ស្លូតណាស់អត់មានអីទេ គាត់អត់ចេះឡូឡាអីទេ។

កៈ ចា៎ចុះអ៊ំគឹមហាក់វិញ?

ខៈ មួយនេះកាចតិចដែរប៉ុន្តែគ្នាក៏ស្លូតដែរ កាចតែបន្តិចៗទេ ប៉ុន្តែស្រលាញ់ខ្ញុំខ្លាំងណាស់!!

កៈ តើឥឡូវពួកគាត់ប្រកបមុខរបរអ្វី?

ខៈ ពីមុនគាត់ធ្វើការដែរតែឥឡូវគាត់ឈឺ គាត់អត់បានធ្វើការគាត់នៅផ្ទះ។

កៈ ចុះអំពីវិញឥឡូវ?

ខៈ អើខ្ញុំរាល់ថ្ងៃធ្វើសន្តិសុខ ភី ស៊ី អេស។

កៈ ចាំ!!

ណៈហ្នឹងហើយយាមនៅព្រះវិហារតាខ្មៅ។

កៈ តើរបៀបដែលចិញ្ចឹមនឹងអប់រំកូនដោយរបៀបណា?

ខៈ អើខ្ញុំមិនសូវបានប្រដៅប៉ុន្មានទេ បើនិយាយរួមទៅ បើនិយាយរបៀបខ្មែរយើងគេហៅថាកូនតពូជហាំឥឡូវ!!

កៈ ចាំ!!

ខៈ គឺតពូជអ្វីដែលឪពុកម្ដាយយ៉ាងម៉េចគឺកូនចឹងដែរ ញ៉ុមអត់សូវ បានប្រដៅច្រើនហាំ!!

កៈ ចាំ!!តើមានអោយកូនទៅទទួលការសិក្សាទេ?

ខៈ សិក្សាណា?សិក្សាម៉េច?

កៈ គឺសាលារៀន។ អោយចូលរៀនចូលអី!!!

ខៈ ហ្ហំទាំងអស់គ្នា១០នាក់រៀនទាំងអស់។

កៈ អត់មានអត់មានទេ?

ខៈ អត់មានអត់ទេ រៀនទាំងអស់ហើយមានបានទៅក្រៅទៀតហ្ហំ!!

កៈ ចាំ ចឹងឡូយណាស់!!ហេតុអ្វីអោយកូនទៅសិក្សា?

ណៈដោយសារនេះគឺជាអនាគតដ៏ភ្លឺស្វាងរបស់វាទៅថ្ងៃក្រោយ គឺសំខាន់បំផុតហ្នឹងគឺការសិក្សាហ្នឹងឯង។

កៈ តើតំលៃនៃការអប់រំមានតំលៃយ៉ាងណាចំពោះប៉ា?

ខៈ អប់រំគឺសំខាន់ខ្លាំងសំរាប់មិនថាខ្ញុំមិនថាអ្នកណាទេ គឺការអប់រំសំខាន់ណាស់ បើអត់មានការអប់រំទេយើងច្បាស់ជាមិនដឹងក្លាយជាមនុស្សអីទេ!! ក្លាយជាមនុស្សមហិចតា មនុស្សលោភលន់ មនុស្សឆ្កួត មនុស្សវង្វេង មនុស្សយ៉ាងម៉េចៗគ្រប់បែបយ៉ាងទាំងអស់ ទៅតាមលោកិយបង្វក់។

កៈ តើត្រូវធ្វើយ៉ាងម៉េចដើម្បីអោយក្រុមគ្រួសារមានសុភមង្គល?

ខៈ គឺសំខាន់បំផុតក្តីស្រលាញ់ហ្នឹងឯង យល់ចិត្តគ្នាអធ្យាស្រ័យគ្នាទៅវិញទៅមក។

កៈ តើគ្រួសារមានបញ្ហា តើមានវិធីអ្វីដើម្បីដោះស្រាយ?

ខៈ គឺដោះស្រាយតាមរបៀបសន្តិវិធី គឺត្រូវមានការប្រជុំដូចយើងរាល់ថ្ងៃយើងមានខាងសាសនាព្រះអង្គចឹងយើងមានធ្វើរាត្រីក្រុមគ្រួសារ យើងពិភាក្សាគ្នាដោយអត់មានកំហឹងកំហាល់អីទេ យើងនិយាយគ្នាធម្មតា។

កៈ តើគ្រួសារមានអត្ថន័យយ៉ាងណាចំពោះប៉ា ?

ខៈ គ្រួសារគឺសំខាន់បើកាលណាអត់មានគ្រួសារគេហៅថាយើងនៅតែលតោល ដោយសារប៉ា ប៉ាដឹងថាមានតែម្នាក់ឯងហើយ អត់មានបងប្អូនបង្កើតទេដូច្នេះយើងត្រូវតែមានក្រុមគ្រួសារគឺសំខាន់មែនទែន!!!

កៈ តើប៉ាមានបទពិសោធន៍អ្វីខ្លះដែលល្អក្នុងជីវិតចង់ចែកចាយទៅកាន់កូនចៅជំនាន់ក្រោយ?

ខៈ សួរម្តងទៀត!!

កៈ តើប៉ាមានបទពិសោធន៍អ្វីខ្លះដែលល្អៗក្នុងជីវិតចង់ចែកចាយទៅកាន់កូនចៅជំនាន់ក្រោយ

ណៈពិសោធន៍ល្អៗនេះគឺយើងប្រឹងរៀន យើងប្រឹងអាន យើងប្រឹងអ្វីមើលទៅតែគំរូល្អ គំរូអាក្រក់ៗយើងកុំមើល ដូចយើងឥឡូវនេះ សម័យយើងឥឡូវនេះយើងដឹងហើយថាបើយើងខ្វះខាតពេកក៏យើងអាក្រក់មើលដែរ ធ្វើម៉េចអោយមួយសមរម្យ ទាំងចំនេះវិជ្ជា ទាំងការងារ ទាំងសំភារះប្រើប្រាស់ ទាំងរូបរាងកាយរបស់យើង ធ្វើម៉េចអោយបានសមរម្យនឹងគេនឹងឯង។

កៈ តើមានជំបូន្មានអ្វីចង់ផ្តាំផ្ញើទៅកាន់កូនចៅជំនាន់ក្រោយ? សំណួរចុងក្រោយហ៎អ៊ំ!!

ខៈ ចុងក្រោយបង្អស់ចង់ផ្តែផ្តាំកូនចៅជំនាន់ក្រោយហ្នឹងគឺយើងត្រូវតែស្រលាញ់ក្រុមគ្រួសារ ស្រលាញ់ប្រទេសជាតិ ស្រលាញ់អ្វីដែលជាទំនៀមទំលាប់ដូនតាយើងពីដើមមក កុំអោយបាត់បង់ ហើយយើងលើកស្ទួយក្រុមគ្រួសារយើង លើកស្ទួយប្រទេសជាតិយើងអោយបានរីកសុសសាយដូចជាអច្ឆរិយប្រទេស។

កៈ ចឹងអ៊ំដូចជាមានចង់ផ្តល់ជំបូន្មានអោយគាត់ជៀសផុតពីផ្លូវអីទេ?

ខ៖ ហ្នឹងហើយ យើងដឹងហើយថាផ្លូវអាក្រក់ច្រើនណាស់នៅលើលោកិយយើងនៅលើផែនដីយើងហើយបើផ្លូវអាក្រក់ចឹងយើងឃើញហើយយើងជៀសទៅហាំ!! ទាំងការហូបចុកអីមានគ្រឿងញៀន មានបារីមានអើផ្ទាំអីគ្រប់បែបយ៉ាងនេះញ៉ុមមិនស្គាល់ទេណាស់!!!អត់ស្គាល់ទេលឺសូរតែគេផ្សាយនៅក្នុងវិតយោរ ផ្សាយរាល់ថ្ងៃហ្នឹងយើងកុំប៉ះពាល់វាទៅបានហើយ!!

កៈ ចាំ!!!

ចឹងទីបញ្ចប់ញ៉ុមសូមថ្លែងអំណរគុណសំរាប់ការសំភាសន៍នៅក្នុងថ្ងៃនេះអ្វីៗទាំងអស់នេះកូនចៅរបស់ប៉ាបានដឹងលឺនៅក្នុងប្រវិត្តរបស់ប៉ាហើយពួកយើងនឹងដាក់ចូលការសំភាសន៍នេះនៅក្នុងវេបសាយនៅខាងលើសូមអរគុណ។

ខ៖ អើខ្ញុំក៏អរគុណដែរ ដែលបានមកសំភាសន៍ខ្ញុំទាំងកូនទាំងក្មួយស្រីអរគុណច្រើនណាំ!!!

កៈ ចាំ!!!!